# យោបល់ទូទៅលេខ ២៦

របស់គណៈកម្មាធិការសិទ្ធិកុមារនៃ
អង្គការសហប្រជាជាតិ

ស្តីពី

# សិទ្ធិរបស់កុមារ និងបរិស្ថាន ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការប្រែប្រួលអាកាសធាតុ



សំណៅ (ឯកសារ) សម្រាប់កុមារ

ឆ្នាំ២០២៣



អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិកុមារ គឺជាកិច្ចព្រមព្រៀងសំខាន់មួយ ដែលបណ្តាប្រទេសទាំងឡាយសន្យាក្នុងការការពារសិទ្ធិកុមារ។ អនុសញ្ញានេះពន្យល់ថា តើកុមារគឺជានរណា ក៏ដូចជាសិទ្ធិទាំងអស់របស់ពួកគេ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងការការពារ លើកកម្ពស់ និងបំពេញសិទ្ធិរបស់កុមារ។

គណៈកម្មាធិការសិទ្ធិកុមារ គឺជាក្រុមមួយ ដែលមានអ្នកជំនាញផ្នែកសិទ្ធិកុមារចំនួន ១៨នាក់ មកទូទាំងពិភពលោក ។ គណៈកម្មាធិការនេះជួបប្រជុំគ្នាចំនួនបីដងក្នុងមួយឆ្នាំ នៅទីក្រុងហ្សឺណែវប្រទេសស្វីសដើម្បីពិភាក្សាអំពីរបៀបលើកកម្ពស់និងការពារសិទ្ធិរបស់កុមារនៅក្នុងប្រទេសនីមួយៗ ដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ។ គណៈកម្មាធិការនេះក៏ផ្តល់អនុសាសន៍ទៅដល់ប្រទេសនីមួយៗអំពី របៀបដែលប្រទេសទាំងនោះគួរពង្រឹងសិទ្ធិរបស់កុមារផងដែរ។

គណៈកម្មាធិការនេះបានរៀបចំឯកសារមួយឈ្មោះថា យោបល់ទូទៅ ដែលពន្យល់ដល់រដ្ឋាភិបាលថា តើសិទ្ធិរបស់កុមារមានទំនាក់ទំនងជាមួយនឹងបរិស្ថាននិងការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេចនិងអ្វីដែលរដ្ឋាភិបាលត្រូវតែធ្វើ ដើម្បីការពារសិទ្ធិទាំងនេះ។ នៅពេលនេះ អ្នកកំពុងអានសំណៅមួយនៃយោបល់ទូទៅ ដែលត្រូវបានបង្កើតឡើងសម្រាប់កុមារ ជាមួយនឹងសមាជិកនៃក្រុមប្រឹក្សាយោបល់កុមារ សម្រាប់យោបល់ទូទៅលេខ ២៦។

# សេចក្តីផ្តើម

គ្រោះថ្នាក់ផ្នែកបរិស្ថាន គឺជាការគំរាមកំហែងគួរឱ្យកត់សម្គាល់ចំពោះសិទ្ធិរបស់កុមារនៅទូទាំងសកលលោក។ កុមារកំពុងត្រូវការវិធានការជាបន្ទាន់ ហើយសិទ្ធិរបស់ពួកគេត្រូវតែទទួលបានការការពារ។ បរិស្ថានស្អាត មានសុខភាពល្អ និងប្រកបដោយចីរភាព គឺជាបញ្ហាសិទ្ធិមនុស្ស និងជាការចាំបាច់ ដើម្បីឱ្យកុមារទទួលបានសិទ្ធិរបស់ពួកគេ។ យោបល់ទូទៅនេះពន្យល់ថា ហេតុអ្វីបានជាចាំបាច់ត្រូវមានវិធានការជាបន្ទាន់ផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុ និងអ្វីដែលរដ្ឋាភិបាលត្រូវតែធ្វើ ដើម្បីការពារសិទ្ធិទាំងអស់ ដែលកុមារមាន។ យោបល់ទូទៅនេះបង្ហាញច្បាស់ថា រដ្ឋាភិបាលត្រូវតែការពារសិទ្ធិរបស់កុមារនៅពេលបច្ចុប្បន្ន ព្រមទាំងកុមារនៅជំនាន់ក្រោយ។

កិច្ចខិតខំប្រឹងប្រែងរបស់កុមារក្នុងការក្រោកឈរឡើងដើម្បីសិទ្ធិក្នុងការទទួលបានបរិស្ថានរបស់ពួកគេបានជំរុញឱ្យគណៈកម្មាធិការនេះបង្កើតយោបល់ទូទៅនេះ។ កុមារបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់រូបរាងនៃយោបល់ទូទៅនេះ៖ កុមារចំនួន ១៦.៣៣៣នាក់ មកពី ១២១ប្រទេសបានចែករំលែក នូវទស្សនៈ និងគំនិតរបស់ពួកគេនៅក្នុងកិច្ចពិគ្រោះយោបល់នានា ដែលត្រូវបានរៀបចំរចនាជាមួយសមាជិកនៃក្រុមប្រឹក្សាយោបល់កុមារសម្រាប់យោបល់ទូទៅលេខ ២៦។ សម្រង់ឃ្លាមួយ (ដំណកស្រង់)ពីកុមារនៅក្នុងកំឡុងពេលដែលកិច្ចពិគ្រោះយោបល់យោបល់ទូទៅ បានកើតឡើង។

"ខ្ញុំចង់ប្រាប់ពួកគេ [មនុស្សពេញវ័យ] ថា យើងគឺជាជំនាន់ក្រោយ (អនាគត) ហើយប្រសិនបើអ្នកបំផ្លាញភពផែនដីនេះ តើយើងនឹងរស់នៅឯណា?!

(កុមារាអាយុ១៣ឆ្នាំ មកពីប្រទេសឥណ្ឌា)

---

វីដេអូគំនូរជីវចល និងសំណៅជាផ្ទាំងផ្សព្វផ្សាយសម្រាប់កុមារ រួមជាមួយនឹងដំណកស្រង់នានាពីកុមារនៅក្នុងយោបល់ទូទៅនេះមាននៅក្នុង៖

childrightsenvironment.org

# តើសិទ្ធិកុមារមានទំនាក់ទំនងជាមួយនឹងបរិស្ថាន និងការប្រែប្រួលអាកាសធាតុយ៉ាងដូចម្ដេច?

សិទ្ធិកុមារទាំងអស់មានទំនាក់ទំនងគ្នា និងមានសារសំខាន់ស្មើៗគ្នា។ សិទ្ធិមួយចំនួនរងការគំរាមកំហែងជាក់លាក់ពីគ្រោះថ្នាក់ផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ សិទ្ធិមួយចំនួនក៏ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការជួយការពារសិទ្ធិកុមារផងដែរ ដូចជា សិទ្ធិរបស់ពួកគេក្នុងការទទួលបានការអប់រំ។




## មាត្រា ២ សិទ្ធិចំពោះការមិនរើសអើង

គ្រោះថ្នាក់ផ្នែកបរិស្ថានអាចជាការគំរាមកំហែងកាន់តែធំចំពោះក្រុមកុមារជាក់លាក់ជាពិសេស កុមារជនជាតិដើម កុមារមកពីក្រុមជនជាតិភាគតិច កុមារមានពិការភាព និងកុមារកំពុងរស់នៅតាមទីកន្លែងដែលងាយរងផលប៉ះពាល់ខ្លាំងពីគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។ រដ្ឋាភិបាលត្រូវប្រមូលព័ត៌មាន ដើម្បីសិក្សាបន្ថែមទៀតអំពី វិសមភាពរវាងក្រុមទាំងនេះ និងចាត់វិធានការជាក់លាក់ ដើម្បីដោះស្រាយបញ្ហាវិសមភាពទាំងនេះ។ នៅពេលរដ្ឋាភិបាលចាត់វិធានការលើបញ្ហាបរិស្ថាន ពួកគេត្រូវតែយកចិត្តទុកដាក់បន្ថែមទៀតក្នុងការមិនបង្កផលប៉ះពាល់អវិជ្ជមានលើកុមារ។





## មាត្រា ៣ ឧត្តមប្រយោជន៍របស់កុមារ

នៅពេលធ្វើសេចក្ដីសម្រេចអំពី បរិស្ថាន និងការប្រែប្រួលអាកាសធាតុ រដ្ឋាភិបាលត្រូវតែពិចារណា ថាតើកុមារនឹងរងផលប៉ះពាល់ដោយរបៀបណា និងតើរដ្ឋាភិបាលនឹងគាំទ្រដល់សុខុមាលភាព និងការអភិវឌ្ឍរបស់កុមារនៅពេលបច្ចុប្បន្ន និងអនាគតដោយរបៀបណា។

## មាត្រា ៦ សិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍ

កុមារគប្បីអាចរស់នៅ ចម្រើនវ័យ និងអភិវឌ្ឍនៅក្នុងបរិយាកាសសុវត្ថិភាពដែលមានសុខភាពល្អ និងទទួលបានការគាំទ្រ ដែលពួកគេត្រូវការ។ ជីវិតរបស់ពួកគេមិនគប្បីប្រឈមនឹងហានិភ័យដោយសារគ្រោះថ្នាក់ផ្នែកបរិស្ថាន ដូចជា ការបំពុល ឬការប៉ះពាល់ជាមួយនឹងសារធាតុសំណទ្បើយ។



## មាត្រា ១២ សិទ្ធិចំពោះការទទួលបានការស្តាប់ឮ



មនុស្សពេញវ័យគប្បីផ្តល់ការយកចិត្តទុកដាក់ខ្លាំងចំពោះកុមារ ហើយកុមារគប្បីមានសំឡេងទៅលើបញ្ហានានាពាក់ព័ន្ធនឹងបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ រដ្ឋាភិបាលគប្បីបង្កឱ្យមានការចូលរួមរបស់កុមារ នៅពេលធ្វើសេចក្តីសម្រេចអំពី បរិស្ថាន និងការប្រែប្រួលអាកាសធាតុ និងធានាថារដ្ឋាភិបាលផ្តល់យោបល់ត្រលប់ដល់កុមារថា តើមានការពិចារណាយ៉ាងដូចម្តេចចំពោះទស្សនៈរបស់ពួកគេ។

## មាត្រា ១៣, ១៥ សិទ្ធិក្នុងការទទួលបានសេរីភាពនៃការបញ្ចេញមតិ ការជួបជុំ និងការប្រមូលផ្តុំដោយសន្តិវិធី



កុមាររមែងតែងក្រោកឈរឡើងដើម្បីសិទ្ធិផ្នែកបរិស្ថានក្នុងនាមជាអ្នកការពារសិទ្ធិមនុស្ស។ កុមារជាច្រើនក៏ចំណាយពេលជាមួយមិត្តភក្តិ និងក្រុមនានា ដែលពួកគេផ្លាស់ប្តូរព័ត៌មាន និងគំនិតផ្សេងៗដល់គ្នាទៅវិញទៅមក។ រដ្ឋាភិបាលគប្បីគាំទ្រកុមារក្នុងការបង្ហាញមតិយោបល់របស់ពួកគេតាមរយៈការផ្តល់លំហសុវត្ថិភាពនិងដោយមានការផ្តល់ភាពអង់អាចដើម្បីឱ្យកុមារធ្វើកិច្ចការទាំងនោះ។ រដ្ឋាភិបាលគប្បីអនុម័តច្បាប់ ដើម្បីការពារអ្នកការពារសិទ្ធិមនុស្សជាកុមារ។



## មាត្រា ១៣, ១៧ ការទទួលបានព័ត៌មាន

រដ្ឋាភិបាលគប្បីធ្វើឱ្យប្រាកដថាកុមារទទួលបានព័ត៌មានច្បាស់លាស់និងត្រឹមត្រូវអំពីបរិស្ថាននិងការប្រែប្រួលអាកាសធាតុរួមទាំងព័ត៌មានអំពីផែនការនិងសេចក្តីសម្រេចដែលបានធ្វើ និងអំពីវិធានការនានា ដែលកុមារផ្ទាល់អាចធ្វើបាន។ ព័ត៌មានគប្បីត្រូវផ្តល់តាមវិធីខុសៗគ្នាដើម្បីឱ្យកុមារមានវ័យខុសៗគ្នានិងកុមារមកពីគ្រប់សាវតារអាចយល់បាន។

## មាត្រា ១៩ សិទ្ធិក្នុងការមិនទទួលរងអំពើហិង្សាគ្រប់ប្រភេទ

គ្រោះថ្នាក់ផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុអាចនាំឱ្យមានស្ថានភាពអស្ថិរភាព វិវាទ និងវិសមភាពដែលបង្កឱ្យកុមារប្រឈមនឹងហានិភ័យកាន់តែខ្លាំងចំពោះអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្ត។ រដ្ឋាភិបាលគប្បីខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកុមារ តាមរយៈការវិនិយោគលើសេវានានា ដែលរៀបចំសម្រាប់កុមារ និងតាមរយៈការធ្វើការងារដើម្បីដោះស្រាយឫសគល់នៃអំពើហិង្សា។



## មាត្រា ២៤ សិទ្ធិទទួលបានសុខភាព

សុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់កុមារមិនគួររងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ ការបំពុល ប្រព័ន្ធអេកូឡូស៊ីដែលគ្មានសុខភាពល្អ និងការបាត់បង់ជីវចម្រុះឡើយ។ ប្រសិនបើកុមារណាម្នាក់ជួបប្រទះនឹងបញ្ហាសុខភាព ពួកគេត្រូវតែអាចទទួលបានការថែទាំសុខភាព និងកិច្ចគាំទ្រ។



## មាត្រា ២៦, ២៧

## សិទ្ធិទទួលបានសន្តិសុខសង្គម និងស្តង់ដារស់នៅសមរម្យ

កុមារគប្បីអាចទទួលបានអាហារដែលមានសុវត្ថិភាព ទឹកស្អាត ផ្ទះសម្បែងសមរម្យ និងសម្ភារ ដែលចាំបាច់ ដើម្បីឱ្យពួកគេរស់នៅ និងចម្រើនវ័យ។ រដ្ឋាភិបាលត្រូវធ្វើឱ្យប្រាកដថា កុមារមិនកំពុងរស់នៅក្នុងលក្ខខណ្ឌក្រីក្រ ឬអសុវត្ថិភាពឡើយ។

## មាត្រា ២៨, ២៩

## សិទ្ធិទទួលបានការអប់រំ




កុមារគប្បីទទួលបានការអប់រំអំពីបរិស្ថានដែលត្រឹមត្រូវនិងតាមវិធីដែលពួកគេយល់បាន។ការអប់រំអំពី បរិស្ថានគប្បីគាំទ្រកុមារក្នុងការទំនាក់ទំនងជាមួយនឹងបរិស្ថាន និងគោរពបរិស្ថាន។ ទីកន្លែងនានា ដែលកុមាររៀនសូត្រ គប្បីមានសុវត្ថិភាពពីគ្រោះថ្នាក់ផ្នែកបរិស្ថាន។

## មាត្រា ៣០

## សិទ្ធិរបស់កុមារជនជាតិដើម និងកុមារមកពីក្រុមជនជាតិភាគតិច

ជីវិតការរស់រានមានជីវិត និងការប្រតិបត្តិវប្បធម៌របស់កុមារជនជាតិដើម និងកុមារមកពីក្រុមជនជាតិភាគតិចរមែងតែងមានទំនាក់ទំនងខ្លាំងជាមួយនឹងបរិស្ថានជាធម្មជាតិរបស់ពួកគេ។ រដ្ឋាភិបាលគប្បីធានាថា ពួកគេការពារសិទ្ធិរបស់កុមារ និងបង្កការចូលរួមរបស់កុមារនៅក្នុងការធ្វើសេចក្តីសម្រេចរបស់ពួកគេអំពីបរិស្ថាន ។

## មាត្រា ៣១

## សិទ្ធិទទួលបានការសម្រាក និងការលេងកម្សាន្ត

កុមារគប្បីអាចលេង និងធ្វើសកម្មភាពនៅទីកន្លែងស្អាតមានសុវត្ថិភាព និងទំនាក់ទំនងជាមួយនឹងពិភពធម្មជាតិរបស់ពួកយើង។ រដ្ឋាភិបាលត្រូវពិចារណាអំពីទីកន្លែងនិងរបៀបដែលកុមារអាចលេងនិងសម្រាកនៅពេលដែលពួកគេរៀបចំផែនការសម្រាប់តំបន់ជិតខាងឬទីកន្លែងថ្មីៗដែលកុមារអាចទៅលេង។



## សិទ្ធិទទួលបានបរិស្ថានស្អាត មានសុខភាពល្អ និងប្រកបដោយចីរភាព

គណៈកម្មាធិការនេះពន្យល់ថា កុមារមានសិទ្ធិទទួលបានបរិស្ថានស្អាតមានសុខភាពល្អនិងប្រកបដោយចីរភាព។ កុមារត្រូវការបរិស្ថានស្អាត ដើម្បីទទួលបានសិទ្ធិមនុស្សរបស់ពួកគេ។ កុមារគប្បីទទួលបានខ្យល់ និងទឹកស្អាត អាកាសធាតុប្រកបដោយសុវត្ថិភាព ប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះប្រកបដោយសុខភាពល្អ អាហារដែលមានសុខភាពល្អ និងបរិស្ថានដែលគ្មានការបំពុល។

# តើរដ្ឋាភិបាលត្រូវធ្វើអ្វីខ្លះ ដើម្បីការពារសិទ្ធិកុមារ រួមទាំងសិទ្ធិរបស់កុមារក្នុងការទទួលបានបរិស្ថានស្អាត មានសុខភាពល្អ និងប្រកបដោយចីរភាព?




- គោរព ការពារ និងបំពេញសិទ្ធិរបស់កុមារ តាមរយៈការចាត់វិធានការគួរឱ្យកត់សម្គាល់ និងច្បាស់លាស់ និងតាមរយៈការរក្សាការសន្យារបស់ពួកគេ ដើម្បីធានាថា កុមារគ្រប់រូបចម្រើនវ័យនៅក្នុងបរិស្ថានស្អាត មានសុខភាពល្អ និងប្រកបដោយចីរភាព។

- អនុវត្តការវាយតម្លៃផលប៉ះពាល់លើសិទ្ធិកុមារជាប្រចាំ ដើម្បីយល់ (និងដោះស្រាយ)ថាតើសេចក្ដីសម្រេចរបស់ពួកគេអំពីបរិស្ថាននឹងមានផលប៉ះពាល់ (ឬកំពុងមានផលប៉ះពាល់) យ៉ាងដូចម្ដេចចំពោះកុមារ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះរបៀបដែលកុមារគ្រប់វ័យនិងកុមារមកពីគ្រប់សាវតារអាចរងផលប៉ះពាល់ខុសៗគ្នា។

- ធ្វើឱ្យប្រាកដថា ធុរកិច្ចនានាក៏គោរពសិទ្ធិរបស់កុមារផងដែរ តាមរយៈការបង្កើតច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ ដើម្បីទប់ស្កាត់ក្រុមហ៊ុននានាពីការបំពុលបរិស្ថាន និងការបង្កគ្រោះថ្នាក់ចំពោះកុមារ និងធានាថា ធុរកិច្ចនានាមិនលាក់បាំងអំពីផលប៉ះពាល់លើបរិស្ថានរបស់ពួកគេឡើយ។

- ធ្វើឱ្យប្រាកដថា កុមារទទួលបានការគាំទ្រឱ្យទទួលបានភាពយុត្តិធម៌ នោះគឺ ដំណោះស្រាយ កិច្ចគាំទ្រ និងសំណងចំពោះគ្រោះថ្នាក់ និងផលវិបាកដែលពួកគេកំពុងជួបប្រទះ នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

- សហប្រតិបត្តិការជាអន្តរជាតិជាមួយរដ្ឋាភិបាលដទៃទៀត ដោយសារបញ្ហាបរិស្ថានមិនឈប់នៅត្រឹមព្រំដែនរបស់ប្រទេសមួយឡើយ។ បណ្ដាប្រទេសនានា ដែលទទួលខុសត្រូវខ្លាំងបំផុតចំពោះផលប៉ះពាល់អវិជ្ជមានលើបរិស្ថាននិងដែលមានធនធានច្រើនបំផុតគប្បីចាត់វិធានការច្រើនជាងប្រទេសដទៃទៀត និងគាំទ្រប្រទេសនានា ដែលរងផលប៉ះពាល់ខ្លាំងបំផុត។

"ការឡើងកម្ដៅជាសកល និង បញ្ហាផ្សេងទៀតមិនអាចដោះស្រាយបានឡើយ លុះត្រាតែមានកិច្ចសហប្រតិបត្តិល្អជាសាកល។"

(កុមារីអាយុ១១ឆ្នាំមកពីប្រទេសចិន)







រដ្ឋាភិបាលគប្បីពិចារណាលើសិទ្ធិរបស់កុមារនៅក្នុងគ្រប់សេចក្តីសម្រេចអំពីការប្រែប្រួលអាកាសធាតុនិងពិចារណាលើការប្រែប្រួលអាកាសធាតុនៅក្នុងគ្រប់សេចក្តីសម្រេចចិត្ត ដែលពួកគេកំពុងធ្វើពាក់ព័ន្ធនឹងកុមារ។

## ពួកគេគប្បី៖

- កាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នោះគឺ រក្សាការសន្យារបស់ពួកគេក្នុងការដាក់កម្រិតចំពោះការឡើងកម្តៅរបស់ភពផែនកដីអនុវត្តតាមអ្វីដែលអ្នកវិទ្យាសាស្ត្រប្រាប់យើងអំពីការប្រែប្រួលអាកាសធាតុ និងការចាត់វិធានការជាបន្ទាន់។

- រួមបញ្ចូលកុមារនៅក្នុងការរៀបចំផែនការសម្របខ្លួន សេចក្តីសម្រេច និងដំណោះស្រាយ ព្រមទាំងការពារកុមារ ដែលកំពុងជួបប្រទះនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុរួចហើយ។ កិច្ចការនេះរាប់បញ្ចូលទាំងការពង្រឹងអគារសាលារៀន និងបំពង់បង្ហូរទឹក ដើម្បីទប់ទល់នឹងខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុផ្សេងទៀត និងការផ្តល់ការផ្គត់ផ្គង់ស្បៀងអាហារនៅក្នុងករណីមានគ្រោះអាសន្ន។

- ផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសទៅដល់ប្រទេសនានា ដែលកំពុងជួបប្រទះការបាត់បង់ និងការបំផ្លិចបំផ្លាញ ដែលកំពុងមានផលប៉ះពាល់លើសិទ្ធិរបស់កុមារ។

- ធ្វើឱ្យប្រាកដថា ធុរកិច្ចនានា រួមទាំងធុរកិច្ចជាសកលនៅក្នុងប្រទេសច្រើនជាងមួយ មិនបង្កផលប៉ះពាល់អវិជ្ជមានលើសិទ្ធិរបស់កុមារ តាមរយៈការធានាថា ធុរកិច្ចទាំងនោះកាត់បន្ថយការបំភាយឧស្ម័នយ៉ាងឆាប់រហ័ស របស់ពួកគេ និងលើកទឹកចិត្តឱ្យមានថាមពលកកើតឡើងវិញ។

- ធ្វើឱ្យប្រាកដថា ហិរញ្ញប្បទានអាកាសធាតុមិនគាំទ្រដល់សកម្មភាព ដែលរំលោភសិទ្ធិរបស់កុមារឡើយ។



"មនុស្សពេញវ័យ [គប្បី] ឈប់ធ្វើសេចក្តីសម្រេច សម្រាប់ពេលអនាគត ដែលពួកគេនឹងមិនជួបប្រទះ។ [យើង] គឺជាមធ្យោបាយគន្លឹះចំពោះការដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយសារវាជាជីវិត [យើង] ដែលប្រឈមនឹងហានិភ័យ។"

(កុមារីអាយុ ១៧ឆ្នាំមកពីប្រទេសក្រូអាត)



# General Comment

Child rights, environment and climate change



អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា

CHILD RIGHTS COALITION CAMBODIA

Terre des Hommes
International Federation

Children's
Environmental
Rights Initiative